សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលនៃសន្និសីទ UNFCCC-CoP-19

ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣ ភ្នំពេញ

# លទ្ធផលនៃ ADP នៅក្នុង COP 19


**ដោយ លោក ជា ច័ន្ទន៍ធូរ**

អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ

ក្រសួងបរិស្ថាន

# សាវតានៃ ADP

- *ក្រុមការងារពិសេសទទួលបន្ទុកវេទិកាក្រុងឌូបាន* សម្រាប់ពង្រឹងសកម្មភាព: ADP
- បានប្រកាសចាប់ផ្តើម ADP នៅឆ្នាំ ២០១១ នៅក្នុង COP 17 នៅឌូបាន ដែលមានអាណត្តិ *"ដើម្បីបង្កើតពិធីសារ បរិធានច្បាប់មួយផ្សេងទៀត ឬ លទ្ធផលដែលបានឯកភាពគ្នា ដែលមានអំណាចតាមផ្លូវច្បាប់នៅក្រោមអនុសញ្ញា ដែលពាក់ព័ន្ធសម្រាប់ភាគីទាំងអស់។"* លើសពីនេះ ADP ក៏មានអាណត្តិ ដើម្បីស្វែងយល់ពីសកម្មភាពដើម្បីសម្រេចបានចំណុចនានាដែលនៅសេសសល់(មហិច្ឆិតាដែលមិនទាន់សម្រេចបាន) នៅមុនឆ្នាំ២០២០ផងដែរ ទាក់ទងនឹងគោលដៅកំហិតកំណើនសីតុណ្ហភាពត្រឹម ២°C
- ADP បានគ្រោងបង្ហើយការចរចានានានៅឆ្នាំ ២០១៥។ បរិធានថ្មីៗ គួរតែចូលជាធរមានចាប់ពីឆ្នាំ ២០២០តទៅ។

# លទ្ធផលនៃ ADP នៅក្នុង COP 19 (1)

- ការងារនៅក្រោម ADP 2-3 បានផ្អែកលើរបៀបវារៈដែលបានអនុម័តនៅក្នុងផ្នែកទី ១ នៃADP 2, ADP ដែលចែកជាចរន្តការងារចំនួន២ (WS),
- WS 1: (កិច្ចព្រមព្រៀងឆ្នាំ 2015) បានពិភាក្សា អំពីមាតិកានិងធាតុសំខាន់ៗនៃកិច្ចព្រមពៀងឆ្នាំ ២០១៥ ដែលរួមទាំង ការបន្សាំ ការកាត់បន្ថយ បច្ចេកវិទ្យា ហិរញ្ញវត្ថុ ការកសាងសមត្ថភាព និងតម្លាភាព
- WS 2: (មហិច្ឆិតានៅមុនឆ្នាំ ២០២០) បានពិភាក្សាអំពីជំហានខាងមុខ ក៏ដូចជា សិក្ខាសាលាស្តីពីមេរៀនដែលទទួលបានពីបទពិសោធន៍នានាដែលពាក់ព័ន្ធទាក់ទងនឹងកិច្ចព្រមព្រៀងពហុភាគីផ្សេងទៀតស្តីពីបរិស្ថាន និងអំពីមហិច្ឆិតានៅមុនឆ្នាំ ២០២០, ការអភិវឌ្ឍទីក្រុង និងតួនាទីរបស់រដ្ឋាភិបាលនៅក្នុងការសម្រួលដល់សកម្មភាពអាកាសធាតុក្នុងទីក្រុង។

# លទ្ធផលនៃ ADP នៅក្នុង COP 19 (2)

- នៅក្នុងការបូកសរុបរបស់ខ្លួន (FCCC/ADP/2013/L.4), ADP អញ្ជើញភាគីនានា និងបានអនុញ្ញាតឲ្យអង្គការដែលជាអ្នកសង្កេតការណ៍ ដាក់ជូនព័ត៌មានស្ដីពីឱកាសដើម្បីធ្វើសកម្មភាពដែលមានសក្ដានុពលខ្ពស់ក្នុងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលរួមទាំង អត្ថប្រយោជន៍ពីការកាត់បន្ថយ ថ្លៃចំណាយ និងអត្ថប្រយោជន៍បន្ថែម និងឧបសគ្គ ចំពោះការអនុវត្ត និងយុទ្ធសាស្ត្រ ដើម្បីជំនះឧបសគ្គទាំងនោះ ដែលរួមទាំង ហិរញ្ញវត្ថុ បច្ចេកវិទ្យា និងការគាំទ្រដល់ការកសាងសមត្ថភាពសម្រាប់ធ្វើសកម្មភាពកាត់បន្ថយ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

# លទ្ធផលនៃ ADP នៅក្នុង COP 19 (3)

**នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន (FCCC/ADP/2013/L.4/Add.1), កិច្ចប្រជុំ COP:**

- ព្រមានថា ការប្រែប្រួលអាកាសធាតុតំណាងឲ្យការគំរាមកំហែងបន្ទាន់ចំពោះសង្គមមនុស្ស ដែលរួមទាំងមនុស្សជំនាន់ក្រោយ និងផែនដីទាំងមូល និងអាចធ្វើឲ្យស្ថានភាពលែងវិលមករកភាពដើមវិញបាន
- គូសបញ្ជាក់អំពីភាពខ្វះចន្លោះសំខាន់ៗ រវាងឥទ្ធិពលសរុបនៃការសន្យារបស់ភាគីនានាក្នុងការកាត់បន្ថយ និងលំនាំនៃការបំភាយសរុប ដែលស្របគ្នាជាមួយឱកាសដែលអាចមាន ដើម្បីកំហិតចំពោះកំណើនសីតុណ្ហភាពជាមធ្យមត្រឹមក្រោម ២°C ឬ ១,៥°C ខ្ពស់ជាងកម្រិតសីតុណ្ហភាពនៅមុនបដិវត្តន៍ឧស្សាហកម្ម
- អះអាងថា ការសម្រេចគោលដៅចុងក្រោយនៃអនុសញ្ញានេះ នឹងទាមទារឲ្យមានការពង្រឹងគោលការណ៍ដែលផ្អែកលើបរិធានពហុភាគី និងការអនុវត្តជាបន្ទាន់និងដែលមាននិរន្តរភាពនូវការប្ដេជ្ញាដែលមានស្រាប់នានានៅក្រោមអនុសញ្ញានេះ
- អំពាវនាវដល់ភាគីទាំងអស់នៃពិធីសារក្យូតូ ឲ្យផ្ដល់សច្ចាប័ននិងអនុវត្តអត្ថបទវិសោធនកម្មដូហា

# លទ្ធផលនៃ ADP នៅក្នុង COP 19 (4)

- សង្កត់ធ្ងន់អំពីតម្រូវការជាបន្ទាន់ឲ្យមានការពង្រឹងសកម្មភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិលើការបន្សាំ ដើម្បីសម្រួលដល់ការអនុវត្ត និងគាំទ្រដល់ការអនុវត្តសកម្មភាពបន្សាំ ក្នុងគោលដៅកាត់បន្ថយភាពងាយរងគ្រោះ និងកសាងភាពធន់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដោយគិតគូរផងដែរអំពីតម្រូវការជាបន្ទាន់ និងចំពោះមុខនៃប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស ប្រទេសកំពុងអភិវឌ្ឍន៍ដែលងាយរងគ្រោះ
- ស្នើដល់ ADP ឲ្យបែងពិស្តារជាបន្ថែមនូវចំណុចនានាសម្រាប់បង្កើតសេចក្តីព្រាងមួយ
- ការចរចាលើអត្ថបទ ដោយគិតបញ្ចូលផងដែរនូវការងាររបស់ខ្លួន និងរួមបញ្ចូល *ការកាត់បន្ថយ ហិរញ្ញវត្ថុ ការអភិវឌ្ឍនិងការផ្ទេរបច្ចេកវិទ្យា* ការកសាងសមត្ថភាព និងតម្លាភាពនៃសកម្មភាព និងការគាំទ្រ

# លទ្ធផលនៃ ADP នៅក្នុង COP 19 (5)

- អញ្ជើញភាគីទាំងអស់ឲ្យផ្តួចផ្តើម ឬ បង្កើនការត្រៀមរៀបចំនៅក្នុងប្រទេស ដើម្បីរួមវិភាគទាននៅថ្នាក់ជាតិទៅតាមការប្តេជ្ញាកន្លងមក ដោយមិនគិតពីប្រភេទនៃវិភាគទានទាំងនោះឡើយ នៅក្នុងបរិបទនៃការអនុម័តពិធីសារមួយ ពោលគឺបរិធានច្បាប់បន្ថែមទៀត ឬ លទ្ធផលដែលបានឯកភាពគ្នា ដែលមានអំណាចតាមផ្លូវច្បាប់នៅក្រោមអនុសញ្ញានេះ និងដែលមានសុពលភាពសម្រាប់ភាគីទាំងអស់ក្នុងការសម្រេចគោលបំណងនៃអនុសញ្ញានេះ *និងធ្វើការប្រាស្រ័យទាក់ទងអំពីវិធានទានទាំងនោះឲ្យបានមុន COP 21 (នៅត្រីមាសទីមួយឆ្នាំ ២០១៥ ពីសំណាក់ភាគីនានា ដែលបានត្រៀមលក្ខណៈជាស្រេចដើម្បីធ្វើបែបនេះ) ដោយមិនគិតអំពីអនុភាពតាមផ្លូវច្បាប់នៃវិភាគទានទាំងនោះឡើយ។*
- ស្នើទៅ ADP ឲ្យកំណត់អត្តសញ្ញាណ នៅមុន COP 20 ព័ត៌មាន ដែលភាគីនានាត្រូវផ្តល់ នៅពេលលើកសំណើវិភាគទានរបស់ខ្លួន ដោយមិនគិតអំពីសុពលភាពច្បាប់នៃវិភាគទានទាំងនោះឡើយ។

# លទ្ធផលនៃ ADP នៅក្នុង COP 19 (6)

- អំពាវនាវ និងស្នើទៅភាគីប្រទេសជឿនលឿន អង្គភាពអនុវត្តនៃយន្តការហិរញ្ញវត្ថុ និងអង្គការនានាដទៃទៀតដែលមានលទ្ធភាពធ្វើបែបនេះ ឲ្យផ្តល់ការគាំទ្រដល់សកម្មភាពដែលពាក់ព័ន្ធឲ្យបានឆាប់តាមតែអាចធ្វើបាន នៅក្នុងឆ្នាំ ២០១៤
- ធ្វើការបង្កើនល្បឿននៃការអនុវត្ត BAP ឲ្យបានពេញលេញ ជាពិសេស ទាក់ទងនឹង មាត្រាស្តីពីមធ្យោបាយអនុវត្ត ការទទួលស្គាល់ថា ការអនុវត្តបែបនេះនឹងពង្រឹងមហិច្ឆិតានៅមុនឆ្នាំ ២០២០
- ធ្វើការពង្រឹងមហិច្ឆិតានៅមុនឆ្នាំ ២០២០ ដើម្បីធានាឲ្យភាគីទាំងអស់ផ្តល់កិច្ចប្រឹងប្រែងកាត់បន្ថយបានខ្លាំងក្លាបំផុតតាមតែអាចធ្វើបាន នៅក្រោមអនុសញ្ញានេះ
- សម្រេចបង្កើនល្បឿននៃសកម្មភាពនានានៅក្រោមផែនការសកម្មភាពនេះស្តីពីការពង្រឹងមហិច្ឆិតាកាត់បន្ថយ
- *ពាក្យដែលមាននៅក្នុងសេចក្តីសម្រេចនៅក្នុង COP 19 ស្តីពីកិច្ចព្រមព្រៀងថ្មី ត្រូវបានបន្ធូរបន្ថយពី "ការប្តេជ្ញា" ទៅជា "ការរួមវិភាគទាន" (លើកស្នើដោយឥណ្ឌា)*

# សូមអរគុណ